ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៦៦.......សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣

# សេចក្តីប្រកាសពត៌មាន

តាងនាមឲ្យរាជរដ្ឋាភិបាល គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាប្រធាននៃគណៈកម្មាធិការនេះ មានកិត្តិយស និងសេក្តីរីករាយ សូមជម្រាបជូនដល់សាធារណជនឲ្យបានជ្រាបអំពីទិន្នន័យនៃកំណើនសេដ្ឋកិច្ច (ផសស) ឆ្នាំ២០១២ និងការព្យាករកំណើន ផសស ឆ្នាំ២០១៣ ដូចតទៅ ៖

## I-កំណើនឆ្នាំ ២០១២

រាជរដ្ឋាភិបាលបានផ្តល់សុពលភាពលើតួលេខកំណើនសេដ្ឋកិច្ច (ផសស) ឆ្នាំ២០១២ មានចំនួន ៧,៣% តាមថ្លៃស្ថេរ និងអត្រាបរិត្តិជរណា (GDP Deflator) មានកំរិត ១,៥% ។ ប្រការដែលកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៧,៣% នោះជាការសម្រេចគោលដៅក្នុងរង្វង់ ៧% ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ក្នុងបរិការណ៍មួយដែលនៅឆ្នាំ ២០១២ រាជរដ្ឋាភិបាលត្រូវគ្រប់គ្រងផលប៉ះពាល់នៃគ្រោះរាំងស្ងួត ការកើនឡើងតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ និង កំណើនសេដ្ឋកិច្ចអាមេរិកនៅទន់ខ្សោយ និង សភាពការណ៍បំណុលនៃសហគមន៍អឺរ៉ុបមិនទាន់មានការដោះស្រាយ ។ ទំហំសេដ្ឋកិច្ច (ផសស) ឆ្នាំ ២០១២ ថ្លៃបច្ចុប្បន្នមានចំនួន ៥៦.៦៨២ ពាន់លានរៀល ឬប្រមាណ ១៤.០៥៤ លានដុល្លារ (អត្រាមធ្យមប្រចាំឆ្នាំគឺ ១ដុល្លារអាមេរិក = ៤.០៣៣ រៀល) និងក្នុងចំនួនប្រជាជន ១៤,៥ លាននាក់ នៅឆ្នាំ ២០១២ ចំណូលរសម្រាប់មនុស្សម្នាក់មានចំនួន ៩៧៣ ដុល្លារអាមេរិក ។

សមាសធាតុនៃកំណើនមានដូចតទៅ៖ (១) ផ្នែកកសិកម្មបានកើនឡើង ៤,៣% ក្នុងនោះវិស័យដំណាំកើនឡើង ៤,៩% និងវិស័យនេសាទត្រីនិងវារីវប្បកម្មកើនឡើង ៦,៧% (២) ផ្នែកឧស្សាហកម្មបានកើនឡើង ៩,៣% ក្នុងនោះវិស័យកម្មន្តសាលកើនឡើង ៦,៩% វិស័យអគ្គិសនី ឧស្ម័ន និងទឹកស្អាតកើនឡើង ៧,៩% និងវិស័យសំណង់កើនឡើង ១៨,២% និង (៣) ផ្នែកសេវាកម្មបានកើនឡើង ៨,១% ក្នុងនោះវិស័យពាណិជ្ជកម្មកើនឡើង ៦,២% វិស័យសណ្ឋាគារនិងភោជនីយដ្ឋានកើនឡើង ១២,៥% វិស័យហិរញ្ញវត្ថុកើនឡើង ១៥% និងវិស័យអចលនទ្រព្យនិងជំនួញកើនឡើង ១២,៩% ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

II-ការព្យាករបឋមកំណើនឆ្នាំ ២០១៣

នៅឆ្នាំ ២០១៣ តាមការព្យាករបឋម ដោយយោងតាមទិន្នន័យស្ថិតិផ្លូវការរបស់ស្ថាប័នពាក់ព័ន្ធ និង តាមសកម្មភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រឹមខែមិថុនា ឆ្នាំ២០១៣ កំណើនសេដ្ឋកិច្ច (ផសស) នៅឆ្នាំ ២០១៣ មានចំនួន ៧,៦% តាមថ្លៃថេរ ទន្ទឹមនឹងអត្រាបរិត្តិផរណា (GDP deflator) មានកំរិត ០,៨%, លើកលែងតែមានគ្រោះធម្មជាតិ និងឥទ្ធិពលអាក្រក់ពីកត្តាផ្សេងៗពីពេលនេះដល់ដំណាច់ឆ្នាំ២០១៣ ។ ទំហំសេដ្ឋកិច្ច (ផសស) ថ្លៃបច្ចុប្បន្នឆ្នាំ ២០១៣ អាចនឹងមានចំនួន ៦១.៥២៥ ពាន់លាន រៀល ឬប្រមាណ ១៥.១៩១ លានដុល្លារ (តាមអត្រា ពេលអនុមតិច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ១ដុល្លារអាមេរិក = ៤.០៥០ រៀល) និងក្នុងចំនួនប្រជាជន ១៤,៧ លាននាក់ នៅឆ្នាំ ២០១៣ ចំណូលសម្រាប់មនុស្សម្នាក់មានចំនួន ១.០៣៦ ដុល្លារអាមេរិក ។

តាមការព្យាករនេះ សមាសធាតុនៃកំណើនមានដូចជា៖ (១) ផ្នែកកសិកម្មមានកំណើន ៤,២% ក្នុងនោះវិស័យដំណាំមានកំណើន ៤,១% និងវិស័យនេសាទនិងវារីវប្បកម្មមានកំណើន ៧,១% (២) ផ្នែកឧស្សាហកម្មមានកំណើន ៩,៣% ក្នុងនោះវិស័យកម្មន្តសាលមានកំណើន ៧% វិស័យអគ្គិសនី ឧស្ម័ន និងទឹកស្អាតមានកំណើន ៨,៥% និងវិស័យសំណង់មានកំណើន ១៧,២% និង (៣) ផ្នែកសេវាកម្មមានកំណើន ៨,៨% ក្នុងនោះ វិស័យពាណិជ្ជកម្មមានកំណើន ៧,៧% វិស័យសណ្ឋាគារនិងភោជនីយដ្ឋានមានកំណើន ១៣,៧% វិស័យហិរញ្ញវត្ថុមានកំណើន ១២,៣% និងវិស័យ អចលនទ្រព្យនិងជំនួញមានកំណើន ១០,៩% ។

*

*     *

លទ្ធផលផ្លែផ្កាជាវិជ្ជមានខាងលើនេះ សម្រេចបានក្រោមបរិស្ថានគ្របដណ្តប់នៃសន្តិភាព និងស្ថេរភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា និង ក្រោមការដឹកនាំផ្ទាល់និងជាប្រចាំប្រកបដោយភាពវៃឆ្លាស ពោរពេញដោយបញ្ញាញាណ និងគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជារវគ្គបញ្ញាការតែមួយគត់ ក្នុងការគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាពត៌មាន តាមការគួរ ។

**គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**